Australian Government
Medicare Australia

medicare

# មេឌីឃែរ (Medicare)

## តើ Medicare គឺជាអ្វី?

Medicare (មេឌីឃែរ) គឺជាកម្មវិធីមួយដែលចាត់ចែងដោយ Medicare Australia (មេឌីឃែរអូស្ត្រាលី) ដែលធានាថាប្រជាពលរដ្ឋអូស្ត្រាលីទាំងអស់អាចទទួលការថែទាំព្យាបាលជំងឺ ភ្នែក និងមន្ទីរពេទ្យដោយឥតគិតថ្លៃ ឬបង់ថ្លៃយ៉ាងទាបនៅក្នុងពេលដែលមានសេរីភាពផងដែរក្នុងការជ្រើសយកសេវា (កិច្ចបំរើ) សុខភាពឯកជន។

Medicare ផ្តល់ពលរដ្ឋឲ្យទទួលបាន៖

- ការព្យាបាលដោយឥតគិតថ្លៃក្នុងភាពជាអ្នកជំងឺ (Medicare) សាធារណៈ នៅក្នុងមន្ទីរពេទ្យសាធារណៈណាមួយ
- ការព្យាបាលដោយឥតគិតថ្លៃ ឬចុះថ្លៃដោយគ្រូពេទ្យទាំងឡាយ ដូចជាវេជ្ជបណ្ឌិត ដោយមានរួមទាំងអ្នកឯកទេស អ្នកពិនិត្យភ្នែក និងគ្រូពេទ្យធ្មេញដែលចូលរួមទាំងពួង (សេវាជាក់លាក់តែប៉ុណ្ណោះ)។

ប្រព័ន្ធមន្ទីរពេទ្យសាធារណៈរបស់ប្រទេសអូស្ត្រាលី ទទួលថវិការួមគ្នាពីរដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋាភិបាលថ្នាក់រដ្ឋ និងដែនដី ហើយគ្រប់គ្រងដោយក្រសួងសុខាភិបាលថ្នាក់រដ្ឋ និងដែនដី។ ការបង់ពន្ធ Medicare ឬវិភាគទានរបស់លោកអ្នកចំពោះប្រព័ន្ធថែទាំសុខភាព គឺផ្អែកលើប្រាក់ចំណូលរបស់លោកអ្នក ហើយត្រូវដកហូតតាមរយៈការបង់ពន្ធដារ។

Medicare Australia គ្រប់គ្រង Medicare តាមរយៈបណ្តាញការិយាល័យ Medicare របស់អង្គភាពនេះ ហើយផ្តល់ព័ត៌មានឯទៀត និងសេវាផ្តល់ប្រាក់បំណាច់។

ប្រាក់បំណាច់ដែលលោកអ្នកទទួលពី Medicare គឺផ្អែកលើការតារាងតម្លៃកំណត់ដោយរដ្ឋាភិបាលអូស្ត្រាលី។ វេជ្ជបណ្ឌិតទាំងឡាយអាចគិតថ្លៃឈ្នួលច្រើនជាងតម្លៃកំណត់នេះ។

## តើខ្ញុំមានសិទ្ធិទទួលឬទេ?

ទោះជាលោកអ្នករស់នៅទីណាក៏ដោយនៅក្នុងប្រទេសអូស្ត្រាលី លោកអ្នកមានសិទ្ធិទទួល Medicare គឺឲ្យតែលោកអ្នកមាន៖

- សញ្ជាតិអូស្ត្រាលី
- ទិដ្ឋាការរស់នៅជាអចិន្ត្រៃយ៍
- សញ្ជាតិនូវែលហ្សេឡង់
- ពាក្យសុំទិដ្ឋាការមួយចំនួនសំរាប់រស់នៅជាអចិន្ត្រៃយ៍ ហើយមាន
    - ទិដ្ឋាការមានសុពលភាពមួយ ដោយមានការអនុញ្ញាតឲ្យធ្វើការនៅក្នុងប្រទេសអូស្ត្រាលី ឬ
    - ទិដ្ឋាការមានសុពលភាពមួយ ដោយមានម្តាយឬឪពុក ស្វាមី ឬភរិយា ឬកូនដែលមានសញ្ជាតិអូស្ត្រាលី ឬមានលក្ខណៈសម្បត្តិជាអ្នករស់នៅជាអចិន្ត្រៃយ៍។

**កំណត់សំគាល់៖** Norfolk Island មិនចូលរួមនៅក្នុងកម្មវិធី Medicare ទេ។ ពលរដ្ឋអូស្ត្រាលីដែលបានកំពុងរស់នៅក្នុងប្រទេសអូស្ត្រាលី និងផ្លាស់ទៅរស់នៅ Norfolk Island នឹងមានសិទ្ធិទទួល Medicare នៅពេលវិលមកលេងប្រទេសអូស្ត្រាលីវិញ រហូតដល់ទៅពេលប្រាំឆ្នាំ។

លោកអ្នកប្រហែលជាគ្មានសិទ្ធិទទួល Medicare ទេ បើលោកអ្នក៖

- មានពាក្យសុំទិដ្ឋាការម្ដាយ ឬឪពុកនៅគ្រាសព្វថ្ងៃ ហើយដែលកំពុងទទួលការពិចារណា ឬមានពាក្យសុំទិដ្ឋាការការពារមួយនៅគ្រាសព្វថ្ងៃ ហើយបានដាក់ពាក្យសុំទិដ្ឋាការម្ដាយ ឬឪពុកកាលគ្រាមុន
- មានទិដ្ឋាការបណ្ដោះអាសន្នដោយមានបំណាងរៀបអាពាហ៍ពិពាហ៍ (គូដណ្ដឹង–ថ្នាក់រង 300)។ លោកអ្នកគ្មានសិទ្ធិទទួល Medicare ទេ លុះត្រាតែលោកអ្នកមានពាក្យសុំទិដ្ឋាការរស់នៅជាអចិន្ត្រៃយ៍ ដែលទទួលយកដោយក្រសួងអន្តោប្រវេសន៍ និងកិច្ចការចូលសញ្ជាតិ (DIAC)។

## តើ Medicare ជួយចំណាយលើអ្វីខ្លះ?

Medicare ជួយចេញថ្លៃជូនលោកអ្នកសំរាប់សេវាផ្សេងៗគ្នានៅក្រៅមន្ទីរពេទ្យ និងក្នុងមន្ទីរពេទ្យ។

### សេវាក្រៅមន្ទីរពេទ្យ

សេវាដែល Medicare ជួយចេញថ្លៃឲ្យមានរួមទាំង៖

- ថ្លៃពិគ្រោះយោបល់សំរាប់វេជ្ជបណ្ឌិត និងអ្នកឯកទេស
- តេស្ដ និងការពិនិត្យទាំងឡាយដោយវេជ្ជបណ្ឌិតដែលត្រូវការសំរាប់ព្យាបាលជំងឺ ដោយមានរួមទាំងការថតកាំរស្មី អ៊ិក្ស (x-rays) និងតេស្ដរោគសាស្ត្រ
- តេស្ដភ្នែកដែលធ្វើដោយអ្នកពិនិត្យភ្នែក
- ការវះកាត់ភាគច្រើន និងទម្រង់ការព្យាបាលរោគឯទៀតដែលធ្វើដោយវេជ្ជបណ្ឌិត
- ការវះកាត់ខ្លះដែលធ្វើដោយគ្រូពេទ្យធ្មេញដែលមានការយល់ព្រម
- ទម្រង់ការជាក់លាក់ទាំងឡាយនៅក្រោមគំរោងឆែបបប្ដូរមាត់ និងឆែបក្រអូមមាត់។

លោកអ្នកអាចជ្រើសយកវេជ្ជបណ្ឌិតដែលព្យាបាលលោកអ្នក សំរាប់សេវាដែលផ្ដល់ជូនក្រៅមន្ទីរពេទ្យ។ ដើម្បីទៅជួបអ្នកឯកទេសណាមួយ លោកអ្នកត្រូវមានការបញ្ជូនដោយវេជ្ជបណ្ឌិត (អ្នកឯកទេស ឬគ្រូពេទ្យព្យាបាលជំងឺទូទៅ)។ បើលោកអ្នកពុំមានការបញ្ជូនសមរម្យទេ Medicare ប្រហែលជាមិនចេញថ្លៃជូនលោកអ្នកឡើយ ឬមួយលោកអ្នកប្រហែលជាទទួលចំនួនប្រាក់ដែលកាត់បន្ថយ។ លោកអ្នកមិនចាំបាច់មានការបញ្ជូនទេសំរាប់ការពិគ្រោះយោបល់ជាមួយអ្នកពិនិត្យភ្នែក។

ជាធម្មតា Medicare ចេញថ្លៃចំនួន **85 ភាគរយ**នៃថ្លៃក្នុងតារាងតម្លៃកំណត់របស់ Medicare សំរាប់សេវាក្រៅមន្ទីរពេទ្យដែលមិនមែនជាសេវារបស់គ្រូពេទ្យព្យាបាលជំងឺទូទៅ។

### សេវាក្នុងមន្ទីរពេទ្យ

ប្រទេសអូស្ត្រាលីមានមន្ទីរពេទ្យដែលឧបត្ថម្ភប្រាក់ដោយរដ្ឋាភិបាល ហើយដែលគេស្គាល់ផងដែរថាជាមន្ទីរពេទ្យសាធារណៈ ព្រមទាំងមន្ទីរពេទ្យឯកជន។

#### អ្នកជំងឺសាធារណៈ

បើលោកអ្នកជ្រើសយកការចូលព្យាបាលក្នុងមន្ទីរពេទ្យសាធារណៈជាអ្នកជំងឺ (Medicare) សាធារណៈ លោកអ្នកនឹងទទួលការព្យាបាលដោយវេជ្ជបណ្ឌិត និងអ្នកឯកទេសដែលតែងតាំងដោយមន្ទីរពេទ្យ។ វេជ្ជបណ្ឌិតព្យាបាលនឹងមិនគិតថ្លៃឈ្នួលពីលោកអ្នកសំរាប់ការថែទាំព្យាបាល ឬការថែទាំនៅពេលក្រោយមកទៀតឡើយ។

#### អ្នកជំងឺឯកជន

បើលោកអ្នកជាអ្នកជំងឺឯកជននៅក្នុងមន្ទីរពេទ្យឯកជន ឬសាធារណៈ លោកអ្នកនឹងអាចជ្រើសរើសវេជ្ជបណ្ឌិតដើម្បីព្យាបាល លោកអ្នក។ Medicare នឹងបង់ថ្លៃចំនួន **75 ភាគរយ**នៃថ្លៃក្នុងតារាងតម្លៃកំណត់របស់ Medicare សំរាប់

សេវា និងទម្រង់ការទាំងឡាយដែលផ្តល់ជូនដោយវេជ្ជបណ្ឌិតនានាដែលព្យាបាលលោកអ្នក។ បើលោកអ្នកមានការធានារ៉ាប់រងសុខភាពឯកជន ក្រុមហ៊ុនធានារ៉ាប់រងអាចចេញថ្លៃខ្លះ ឬថ្លៃទាំងអស់សំរាប់ចំនួនដែលនៅសេសសល់។ លោកអ្នកនឹងត្រូវបង់ថ្លៃស្នាក់នៅក្នុងមន្ទីរពេទ្យ ថ្លៃថែទាំព្យាបាល និងមុខចំណាយទាំងឡាយដូចជាថ្លៃវះកាត់ និងថ្នាំពេទ្យ។ លោកអ្នកក៏អាចត្រូវបង់ថ្លៃសេវាសុខភាពពាក់ព័ន្ធទាំងពួងផងដែរ ដូចជាការព្យាបាលដោយចលនាជាដើម។ ក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជនអាចជួយចេញថ្លៃចំណាយទាំងនេះ។

## ការធានារ៉ាប់រងសុខភាពឯកជន

ប្រទេសអូស្ត្រាលីមានក្រុមហ៊ុនធានារ៉ាប់រងសុខភាពមួយចំនួនផ្សេងៗគ្នា និងមានប្រភេទខុសៗគ្នានៃការធានារ៉ាប់រងសុខភាព។

រដ្ឋាភិបាលអូស្ត្រាលីផ្តល់ប្រាក់ឲ្យវិញដល់ទៅ 30 ភាគរយនៃថ្លៃចំណាយប្រភេទភាគច្រើនសំរាប់ការបង់ថ្លៃធានារ៉ាប់រងមន្ទីរពេទ្យឯកជន និងថ្លៃធានារ៉ាប់រងសុខភាពមួយជីវិត ដើម្បីឲ្យរង្វាន់ដល់អ្នកដែលបង់ការធានារ៉ាប់រង និងដែលរក្សាការធានារ៉ាប់រងនោះ។ ការធានារ៉ាប់រងមន្ទីរពេទ្យរបស់លោកអ្នក ក៏មានការរៀបចំខ្លះផងដែរសំរាប់ការបង់ថ្លៃទាំងស្រុងសំរាប់សេវារបស់វេជ្ជបណ្ឌិត នៅពេលដែលលោកអ្នកអញ្ជើញទៅព្យាបាលនៅមន្ទីរពេទ្យ ឬទទួលការវះកាត់នៅពេលថ្ងៃ។

បើលោកអ្នកមានប្រាក់ចំណូលច្រើនជាងចំនួនជាក់លាក់ លោកអ្នកនឹងបង់ពន្ធ Medicare តាមកម្រិតខ្ពស់ បើលោកអ្នកគ្មានការធានារ៉ាប់រងមន្ទីរពេទ្យឯកជនទេនោះ។

## តើខ្ញុំចុះឈ្មោះក្នុង Medicare តាមវិធីណា?

លោកអ្នកត្រូវចុះឈ្មោះក្នុង Medicare ដោយផ្ទាល់ខ្លួននៅឯការិយាល័យ Medicare ណាមួយ។ បើលោកអ្នករស់នៅតំបន់ដាច់ស្រយាល ឬមានមូលហេតុពិតប្រាកដដែលធ្វើឲ្យលោកអ្នកមិនអាចអញ្ជើញទៅកាន់ការិយាល័យ Medicare បាន លោកអ្នកអាចផ្ញើពាក្យសុំរបស់លោកអ្នក ព្រមជាមួយឯកសារដើម ឬឯកសារចម្លងដែលមានការបញ្ជាក់ថាបានចម្លងពីឯកសារដើម ព្រមទាំងបណ្តាមូលហេតុរបស់លោកអ្នកដែលមិនអាចឲ្យទៅជួបដោយផ្ទាល់ខ្លួនទៅកាន់ GPO Box 9822 នៅក្នុងរដ្ឋធានីរបស់លោកអ្នក។ លោកអ្នកនឹងត្រូវបង្ហាញលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរសំរាប់បុគ្គលម្នាក់ៗដែលចុះឈ្មោះនៅក្នុង Medicare ។

**ជនអន្តោប្រវេសន៍ និងអ្នកដាក់ពាក្យសុំរស់នៅជាអចិន្ត្រៃយ៍ (មានរួមទាំងអ្នកដាក់ពាក្យសុំទិដ្ឋាការការពារជាអចិន្ត្រៃយ៍)** នឹងត្រូវផ្តល់ឯកសារជាក់លាក់។

- សំរាប់ជនអន្តោប្រវេសន៍ (អ្នកមានទិដ្ឋាការរស់នៅជាអចិន្ត្រៃយ៍) – លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព។
- សំរាប់អ្នកដាក់ពាក្យសុំរស់នៅជាអចិន្ត្រៃយ៍ – លិខិតឆ្លងដែន ទិដ្ឋាការមានសុពលភាព និងឯកសារពាក់ព័ន្ធណាមួយ ពីក្រសួងអន្តោប្រវេសន៍ និងកិច្ចការចូលសញ្ជាតិ។

នេះត្រូវបានណែនាំថាលោកអ្នកគួររង់ចាំពេល**មួយអាទិត្យ ក្រោយពីលោកអ្នកអញ្ជើញ**មកដល់ប្រទេសអូស្ត្រាលីមុននឹងចុះឈ្មោះ ដើម្បីទុកពេលឲ្យ Medicare ទទួលព័ត៌មានអំពីទិដ្ឋាការរបស់លោកអ្នកពីក្រសួងអន្តោប្រវេសន៍ និងកិច្ចការចូលសញ្ជាតិ។

មន្ត្រីសេវា Medicare ម្នាក់នឹងជួយលោកអ្នកក្នុងការចុះឈ្មោះ។ បើលោកអ្នកត្រូវការជំនួយភាសា មន្ត្រីសេវា Medicare នេះអាចរៀបចំបាន ឬមួយលោកអ្នកអាចទូរស័ព្ទទៅកិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ (TIS) លេខ **131 450***។

### ពលរដ្ឋនូវែលហ្សេឡង់

បើលោកអ្នកមានសញ្ជាតិនូវែលហ្សេឡង់ និងសុំចុះឈ្មោះជាអ្នករស់នៅជាអចិន្ត្រៃយ៍ លោកអ្នកត្រូវយកមកជាមួយនូវ៖

- លិខិតឆ្លងដែននូវែលហ្សេឡង់ ព្រមជាមួយនឹងត្រារបស់ក្រសួងអន្តោប្រវេសន៍ និងកិច្ចការចូលសញ្ជាតិ សំរាប់ចូលមកកាន់ប្រទេសអូស្ត្រាលី
- ឯកសារទាំងឡាយដែលបង្ហាញថា លោកអ្នកបានកាត់ផ្តាច់ចំណងទាក់ទងជាមួយប្រទេសនូវែលហ្សេឡង់ហើយ ឬក៏បង្ហាញនូវការរស់នៅរបស់លោកអ្នកនៅក្នុងប្រទេសអូស្ត្រាលី ហើយនៅក្នុងករណីខ្លះត្រូវមានឯកសារទាំងពីរ។

នៅពេលដែលគ្មានលទ្ធភាពបង្ហាញនូវការរស់នៅ អ្នកមានសញ្ជាតិនូវែលហ្សេឡង់ទាំងឡាយដែលបានកំពុងរស់នៅក្នុងប្រទេសនូវែលហ្សេឡង់មុនចូលមកកាន់ប្រទេសអូស្ត្រាលី មានសិទ្ធិទទួលការព្យាបាលចាំបាច់នៅក្រោមកិច្ចព្រមព្រៀងថែទាំសុខភាពទៅវិញទៅមក។ ការព្យាបាលនេះមានរួមទាំងការព្យាបាលជាអ្នកជំងឺសាធារណៈនៅតាមមន្ទីរពេទ្យសាធារណៈ សេវា អ្នកជំងឺក្រៅមន្ទីរពេទ្យ និងថ្នាំពេទ្យតាមវេជ្ជបញ្ជាដែលចុះថ្លៃឲ្យនៅក្រោមគំរោងជំនួយថ្លៃថ្នាំពេទ្យ។ អ្នកមានសិទ្ធិទទួលទាំងឡាយដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ មិនចុះឈ្មោះនៅក្នុងកម្មវិធី Medicare ឡើយ។

### ទារកទើបកើតថ្មី

ដើម្បីសម្រួលដំណើរការចុះឈ្មោះទារកទើបកើតថ្មី មន្ទីរពេទ្យអាចជួយមាតាបិតាថ្មីក្នុងការបំពេញក្រដាសចុះឈ្មោះដើម្បីផ្ញើទៅកាន់ Medicare ។ ទារកដែលចុះឈ្មោះនៅក្នុង Medicare ក៏ចុះឈ្មោះដោយស្វ័យប្រវត្តិនៅក្នុងបញ្ជីចុះឈ្មោះចាក់ថ្នាំបង្ការរោគកុមារភាពអូស្ត្រាលីផងដែរ។

### ពលរដ្ឋអូស្ត្រាលីវិលត្រឡប់មកពីបរទេសវិញ

បើលោកអ្នកមានសញ្ជាតិអូស្ត្រាលី ដែលវិលមកកាន់ប្រទេសអូស្ត្រាលីវិញ ក្រោយពីរស់នៅបរទេសអស់ពេលច្រើនជាងប្រាំឆ្នាំ លោកអ្នកនឹងត្រូវផ្តល់៖

- ភស្តុតាងនៃសញ្ជាតិអូស្ត្រាលីរបស់លោកអ្នក
- ឯកសារទាំងឡាយដើម្បីជាភស្តុតាងនៃការរស់នៅរបស់លោកអ្នកនៅក្នុងប្រទេសអូស្ត្រាលី ឬការកាត់ផ្តាច់ចំណងទាក់ទងរបស់លោកអ្នកជាមួយនឹងប្រទេសរស់នៅកាលគ្រាមុន ហើយនៅក្នុងករណីខ្លះលោកអ្នកត្រូវមានឯកសារទាំងពីរ។

## តើខ្ញុំនឹងទទួលលេខប័ណ្ណ Medicare របស់ខ្ញុំនៅពេលណា?

បើលោកអ្នកបំពេញតាមតម្រូវការចុះឈ្មោះទាំងអស់ហើយ លោកអ្នកនឹងទទួលលេខប័ណ្ណ Medicare របស់លោកអ្នកនៅពេលលោកអ្នកចុះឈ្មោះ។ ប័ណ្ណ Medicare របស់លោកអ្នកនឹងត្រូវផ្ញើតាមប៉ុស្តិ៍សំបុត្រទៅជូនលោកអ្នកក្នុងរង្វង់ថ្ងៃធ្វើការចំនួន 10 ថ្ងៃ។ នៅពេលលោកអ្នកទទួលប័ណ្ណ Medicare របស់លោកអ្នក សូមឆែកមើលព័ត៌មានឲ្យបានច្បាស់លាស់ ដើម្បីធ្វើឲ្យច្បាស់ថាព័ត៌មានទាំងអស់មានភាពត្រឹមត្រូវ។

ការមានប័ណ្ណ Medicare មួយដែលមានសុពលភាពគឺជាការសំខាន់ណាស់ – ត្រូវធ្វើឲ្យច្បាស់ថា Medicare មានអាសយដ្ឋានគ្រាសព្វថ្ងៃរបស់លោកអ្នកជានិច្ច ដើម្បីឲ្យលោកអ្នកអាចទទួលប័ណ្ណ Medicare ផ្លាស់ថ្មី និងព័ត៌មានសំខាន់ឯទៀត។

សូមយកប័ណ្ណ Medicare របស់លោកអ្នក ឬលេខប័ណ្ណនេះទៅជាមួយលោកអ្នក នៅពេលលោកអ្នក៖

- ទៅជួបវេជ្ជបណ្ឌិតណាមួយ

- ដាក់ពាក្យទាមទារសុំប្រាក់បំណាច់ជាទឹកប្រាក់នៅតាមការិយាល័យ Medicare
- ធ្វើការសាកសួរនៅពេលដាក់ពាក្យទាមទារសុំប្រាក់ទាមទារ
- ជ្រើសយកការព្យាបាលនៅក្នុងមន្ទីរពេទ្យ ក្នុងភាពជាអ្នកជំងឺ (Medicare) សាធារណៈ
- មានវេជ្ជបញ្ជាសំរាប់ទិញថ្នាំពេទ្យនៅឱសថស្ថាន។

## តើខ្ញុំទាមទារសុំប្រាក់ពី Medicare តាមវិធីណា?

លោកអ្នកអាចទាមទារសុំប្រាក់បំណាច់ពី Medicare តាមវិធីច្រើនយ៉ាង។

### នៅឯគ្លីនិកវេជ្ជបណ្ឌិតរបស់លោកអ្នក

ឥឡូវនេះ វេជ្ជបណ្ឌិតជាច្រើនផ្តល់ការទាមទារសុំប្រាក់បំណាច់ពី Medicare តាមបែបអេឡិកត្រូនិក ដោយអនុញ្ញាតឲ្យលោកអ្នកទាមទារសុំប្រាក់បំណាច Medicare របស់លោកអ្នកតាមបែបអេឡិកត្រូនិក ពីគ្លីនិករបស់វេជ្ជបណ្ឌិតលោកអ្នក។

បើវេជ្ជបណ្ឌិតលោកអ្នកផ្តល់ការទាមទារសុំប្រាក់បំណាច់ពី Medicare តាមបែបអេឡិកត្រូនិក បុគ្គលិកគ្លីនិកអាចដាក់ពាក្យសុំទាមទារប្រាក់បំណាច់របស់លោកអ្នកជាមួយនឹង Medicare តាមរយៈការតភ្ជាប់អ៊ីនធើណិតមានសុវត្ថិភាពមួយ ឬតាមរយៈឧបករណ៍ EFTPOS របស់គ្លីនិក ដោយប្រើប័ណ្ណ EFTPOS របស់លោកអ្នក។

ប្រាក់បំណាច់របស់លោកអ្នកនឹងត្រូវប្រគល់ជូនលោកអ្នក ដោយដាក់ចូលទៅក្នុងគណនីធនាគាររបស់លោកអ្នកក្នុងរង្វង់ថ្ងៃធ្វើការចំនួនបីថ្ងៃ ដោយផ្អែកលើប្រព័ន្ធទាមទារប្រាក់ដែលវេជ្ជបណ្ឌិតលោកអ្នកប្រើប្រាស់។

លោកអ្នកអាចចុះព័ត៌មានអំពីគណនីធនាគារលោកអ្នកជាមួយនឹង Medicare Australia ដើម្បីធ្វើឲ្យរឹតតែងាយស្រួលក្នុងការទាមទារសុំប្រាក់បំណាច់ពី Medicare តាមបែបអេឡិកត្រូនិក។ លោកអ្នកអាចធ្វើយ៉ាងនេះដោយបំពេញពាក្យប្រមូលព័ត៌មានអំពីគណនីធនាគារ នៅខាងខ្នងនៃផ្នែកនេះ នៅការិយាល័យ Medicare office តាមវិបសាយ **www.medicareaustralia.gov.au** ឬតាមរយៈការទូរស័ព្ទលេខ **132 011***។ ជាការសំខាន់ផងដែរដែលវេជ្ជបណ្ឌិតលោកអ្នកមានលេខ Medicare និងអាសយដ្ឋានត្រឹមត្រូវរបស់លោកអ្នក។

### ការគិតថ្លៃដោយផ្ទាល់ (Bulk billing)

ការគិតថ្លៃដោយផ្ទាល់គឺនៅពេលដែលវេជ្ជបណ្ឌិតរបស់លោកអ្នកគិតថ្លៃដោយផ្ទាល់ពី Medicare ដោយព្រមទទួលយកប្រាក់បំណាច់របស់ Medicare ជាប្រាក់បង់ពេញលេញសំរាប់សេវារបស់ខ្លួន។ បើវេជ្ជបណ្ឌិតរបស់លោកអ្នកគិតថ្លៃដោយផ្ទាល់ លោកអ្នកមិនបង់ថ្លៃបន្ថែមដូចជាថ្លៃបម្រុងជាមុន ថ្លៃរដ្ឋបាល ការរក្សាកំណត់ត្រា ឬក្រណាត់រុំរបួសទេ។ ប៉ុន្តែប្រហែលជាមានការគិតថ្លៃបន្ថែមសំរាប់ការចាក់ថ្នាំបង្ការរោគមួយចំនួន។

លោកអ្នកមិនចាំបាច់ទាមទារសុំប្រាក់បំណាច់ពី Medicare ទេ ដោយសារតែវេជ្ជបណ្ឌិតរបស់លោកអ្នកនឹងទារយកប្រាក់បំណាច់នេះ ដោយផ្ទាល់ពី Medicare។

### ការិយាល័យ Medicare

Medicare មានការិយាល័យចំនួន 239 នៅជុំវិញប្រទេសអូស្ត្រាលី ដែលអាចឲ្យប្រជាពលរដ្ឋទាមទារសុំប្រាក់បំណាច់នៅតាមការិយាល័យ ឬប្រើប្រអប់ដាក់ពាក្យទាមទារសុំប្រាក់បំណាច់ Medicare ។ លោកអ្នកប្រហែលជាមិនចាំបាច់បំពេញពាក្យទាមទារសុំប្រាក់បំណាច់ទេ នៅពេលទាមទារសុំប្រាក់បំណាច់នៅតាមការិយាល័យ ប៉ុន្តែលោកអ្នកគ្រាន់តែធ្វើឲ្យច្បាស់ថា លោកអ្នកពិតជាមានបង្កាន់ដៃ និងប័ណ្ណ Medicare ។ នៅពេលលោកអ្នកទាមទារសុំប្រាក់បំណាច់នៅតាមការិយាល័យណាមួយ លោកអ្នកអាចទទួលប្រាក់បំណាច់របស់លោកអ្នកជាសាច់ប្រាក់ ឬតាមរយៈប្រព័ន្ធអេឡិកត្រូនិកចូលទៅក្នុងគណនីធនាគាររបស់លោកអ្នក។

## តាមរយៈប៉ុស្តិ៍សំបុត្រ

លោកអ្នកអាចផ្ញើពាក្យដែលលោកអ្នកបំពេញរួចហើយ ព្រមជាមួយនឹងឯកសារដើមពាក់ព័ន្ធនឹងថ្លៃចំណាយ និងបង្កាន់ដៃទាំងឡាយទៅកាន់៖

**Medicare Australia**

**GPO Box 9822**

នៅក្នុងរដ្ឋធានីរបស់លោកអ្នក

សូមកុំផ្ញើប័ណ្ណ Medicare របស់លោកអ្នកឡើយ នៅពេលលោកអ្នកទាមទារសុំប្រាក់តាមប៉ុស្តិ៍សំបុត្រ។ **www.medicareaustralia.gov.au** ឬការិយាល័យ Medicare ទាំងអស់មានពាក្យបំពេញទាំងឡាយ។ នៅពេលលោកអ្នកទាមទារសុំប្រាក់បំណាច់ដោយផ្ញើតាមប៉ុស្តិ៍សំបុត្រ ប្រាក់ទាមទារនេះនឹងត្រូវបង់ចូលតាមរយៈប្រព័ន្ធអេឡិកត្រូនិកទៅក្នុងគណនីធនាគាររបស់លោកអ្នក ឬក៏នឹងផ្ញើសែកមួយជូនលោកអ្នក។

## ទូរស័ព្ទ

ទូរស័ព្ទលេខ **1300 360 460***ផ្តល់ព័ត៌មានអំពីការទាមទារសុំប្រាក់បំណាច់របស់លោកអ្នក បន្ទាប់មកសូមផ្ញើបង្កាន់ដៃ និងឯកសារពាក់ព័ន្ធនឹងថ្លៃចំណាយទៅកាន់៖

**Medicare Australia**

**GPO Box 9822**

នៅក្នុងរដ្ឋធានីរបស់លោកអ្នក

លោកអ្នកមិនចាំបាច់ប្រើពាក្យបំពេញការទាមទារសុំប្រាក់បំណាច់ទេ។ Medicare ចាប់ផ្តើមពិនិត្យមើលការទាមទារសុំប្រាក់បំណាច់របស់លោកអ្នក នៅក្នុងពេលដែលឯកសារទាំងឡាយកំពុងត្រូវបានបញ្ជូនតាមប៉ុស្តិ៍សំបុត្រ។ នៅពេលមានការផ្ទៀងផ្ទាត់រួចហើយ លោកអ្នកនឹងទទួលប្រាក់នេះ។ លោកអ្នកអាចទូរស័ព្ទទៅលេខ **1300 360 460*** ២៤ ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ។ នៅពេលដែលលោកអ្នកទាមទារសុំប្រាក់បំណាច់តាមរយៈទូរស័ព្ទ ប្រាក់ទាមទាររបស់លោកអ្នកនឹងត្រូវប្រគល់ជូនតាមរយៈប្រព័ន្ធអេឡិកត្រូនិកចូលទៅក្នុងគណនីធនាគាររបស់លោកអ្នក ឬក៏នឹងផ្ញើសែកមួយជូនលោកអ្នក។

**Medicare Access Points (កន្លែងទំនាក់ទំនង Medicare)**

អ្នករស់នៅក្នុងសហគមន៍ជនបទ និងដាច់ស្រយាលមានលទ្ធភាពទទួលសេវាតាមរយៈ Medicare Australia Access Points។ Access Points គឺជាតូបតូចទាំងពួងដែលលោកអ្នកអាចពិភាក្សាជាមួយមន្ត្រីសេវា Medicare តាមទូរស័ព្ទ ហើយមានទីតាំងនៅតាមឱសថស្ថាន មណ្ឌលជួញដូរតំបន់ជនបទ និងហាងទំនិញខ្លះ។ ដើម្បីទាមទារសុំប្រាក់បំណាច់ លោកអ្នកនិយាយទៅកាន់អ្នកទទួលទូរស័ព្ទសេវា Medicare តាមទូរស័ព្ទ ដែលគេនឹងកត់ត្រាព័ត៌មានទាំងអស់របស់លោកអ្នក ហើយចាប់ផ្តើមពិនិត្យដោះស្រាយការទាមទារសុំប្រាក់បំណាច់របស់លោកអ្នក។ បន្ទាប់មក លោកអ្នកផ្ញើឯកសាររបស់លោកអ្នកទៅកាន់ Medicare ហើយនៅពេលមានការផ្ទៀងផ្ទាត់ឯកសាររបស់លោកអ្នកហើយ Medicare នឹងបើកប្រាក់ជូនលោកអ្នក។ នៅពេលលោកអ្នកទាមទារសុំប្រាក់បំណាច់តាមទូរស័ព្ទនៅ Access Point ណាមួយ Medicare នឹងប្រគល់ប្រាក់ទាមទាររបស់លោកអ្នកដោយដាក់តាមរយៈប្រព័ន្ធអេឡិកត្រូនិក ចូលទៅក្នុងគណនីធនាគាររបស់លោកអ្នក ឬក៏នឹងផ្ញើសែកមួយជូនលោកអ្នក។

ព្រមជាមួយនឹងការទាមទារសុំប្រាក់បំណាច់របស់លោកអ្នក លោកអ្នកក៏អាចប្រើ Access Points ដើម្បី៖

- សុំរបាយការណ៍ប្រាក់បំណាច់ពន្ធដារ Medicare របស់លោកអ្នក
- កែប្រែព័ត៌មាន Medicare របស់លោកអ្នកដើម្បីឲ្យទាន់សភាពការគ្រាសព្វថ្ងៃ
- ចុះឈ្មោះនៅក្នុងបញ្ជីចុះឈ្មោះអ្នកធ្វើអំណោយសរីរាង្គអូស្ត្រាលី

- ទទួលប្រាក់ជំនួយគ្រួសារ
- ទទួលព័ត៌មានអំពីកម្មវិធីឯទៀតរបស់ Medicare Australia។

លោកអ្នកអាចរកឃើញទីតាំងរបស់ Access Points តាមវិបសាយ **www.medicareaustralia.gov.au**

**Medicare two-way (Medicare ផ្លូវពីរ)**

Medicare two-way អនុញ្ញាតឲ្យលោកអ្នកដាក់ពាក្យទាមទារសុំប្រាក់ Medicare របស់លោកអ្នកនៅឯការិយាល័យនៃក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជនដែលចូលរួមសហការទាំងឡាយ ព្រមទាំងដាក់ពាក្យទាមទារសុំប្រាក់ធានាសុខភាពឯកជនរបស់លោកអ្នកនៅតាមការិយាល័យ Medicare ផងដែរ។ ពាក្យទាមទារសុំប្រាក់របស់លោកអ្នកនឹងត្រូវគេបញ្ជូនទៅកាន់ស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យដោះស្រាយ។ បើលោកអ្នកទាមទារសុំប្រាក់តាមរយៈ Medicare two-way នោះ Medicare នឹងប្រគល់ប្រាក់ទាមទាររបស់លោកអ្នកដោយដាក់តាមរយៈប្រព័ន្ធអេឡិកត្រូនិកចូលទៅក្នុងគណនីធនាគាររបស់លោកអ្នក ឬនឹងផ្ញើសែកមួយជូនលោកអ្នក។

## តើ Medicare Safety Net (សំណាញ់សុវត្ថិភាពមេឌីឃែរ) ជាអ្វី?

បើលោកអ្នកត្រូវទៅជួបវេជ្ជបណ្ឌិតម្នាក់ ឬធ្វើតេស្តទាំងឡាយជាប្រក្រតី លោកអ្នកអាចបង់ថ្លៃពេទ្យយ៉ាងច្រើន។ Medicare Safety Net ត្រូវបានរៀបចំឡើងដើម្បីជួយលោកអ្នក នៅពេលដែលលោកអ្នកត្រូវការជំនួយបំផុត។ នៅពេលដែលលោកអ្នកឈានដល់កម្រិតកំណត់ Medicare Safety Net ហើយ ការទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក ឬការធ្វើតេស្តទាំងឡាយអាចជួយលោកអ្នកក្នុងការបង់ថ្លៃសេវាទាំងនេះ។

Medicare Safety Net ជួយលោកអ្នកក្នុងការបង់**ថ្លៃចំណាយនៅក្រៅមន្ទីរពេទ្យ**។ Medicare Safety Net មិនចេញ ថ្លៃឲ្យសេវាទាំងឡាយដែលលោកអ្នកទទួលនៅក្នុងមន្ទីរពេទ្យ ឬដែលត្រូវបង់ជាការគិតថ្លៃដោយផ្ទាល់ (bulk bill) ឡើយ។

## តើខ្ញុំត្រូវចុះឈ្មោះដែរឬទេ?

**បុគ្គលម្នាក់ៗផ្ទាល់ទាំងឡាយ** ត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ។ លោកអ្នកគ្រាន់តែឲ្យ Medicare មានព័ត៌មានគ្រាសព្វថ្ងៃ សំរាប់ទាក់ទងលោកអ្នកប៉ុណ្ណោះ។

**គ្រួសារ និងគូស្វាមីភរិយា**ទាំងអស់ត្រូវតែចុះឈ្មោះ។ ទោះជាសមាជិកទាំងអស់នៃគ្រួសារលោកអ្នកមានឈ្មោះនៅក្នុងប័ណ្ណ Medicare របស់លោកអ្នកក្តី ក៏លោកអ្នកនៅតែត្រូវចុះឈ្មោះអ្នកទាំងនោះនៅក្នុង Medicare Safety Net ដែរ។

- សមាជិកម្នាក់ៗនៃគ្រួសារត្រូវមានឈ្មោះនៅក្នុងនោះ ដើម្បីឲ្យគេអាចរាប់បញ្ចូលថ្លៃចំណាយព្យាបាលនៅក្រៅមន្ទីរពេទ្យរបស់សមាជិកនោះទៅក្នុង Medicare Safety Net របស់គ្រួសារលោកអ្នក។
- លោកអ្នកត្រូវការចុះឈ្មោះគ្រួសារលោកអ្នកតែមួយលើកប៉ុណ្ណោះ។
- ការចុះឈ្មោះឥតគិតថ្លៃទេ។

កំណត់សំគាល់៖ សំរាប់គោលបំណង Medicare Safety Net គ្រួសារនីមួយៗរួមមាន៖

- ស្វាមីភរិយាមួយគូដែលរៀបការស្របច្បាប់ និងមិនបែកបាក់គ្នា ឬគូកំណាន់មួយគូដែលរស់នៅប្រៀបដូចជារៀបការនឹងគ្នា ដោយមាន ឬគ្មានកូនក្នុងបន្ទុក ឬ
- អ្នកគ្មានគូស្រករដែលមានកូនក្នុងបន្ទុក។

## តើខ្ញុំចុះឈ្មោះតាមវិធីណា?

លោកអ្នកអាចចុះឈ្មោះ៖

- តាមរយៈការបំពេញពាក្យដែលភ្ជាប់ជាមួយនឹងកញ្ចប់នេះ
- ដោយផាល់ខន-នៅឯការិយាល័យ Medicare

- តាមទូរស័ព្ទលេខ **132 011***
- តាមអ៊ីនធើណិត—**www.medicareaustralia.gov.au**

## តើធ្វើដូចម្តេចឲ្យខ្ញុំដឹងថា ការចំណាយរបស់ខ្ញុំកំពុងឡើងជិតដល់កម្រិតកំណត់?

Medicare នឹងទាក់ទងលោកអ្នក នៅពេលដែលការចំណាយរបស់លោកអ្នកកំពុងឡើងជិតដល់កម្រិតកំណត់ហើយនោះ។ ដើម្បីឆែកមើលតុល្យភាព Medicare Safety Net របស់លោកអ្នក៖

- បើកអាន **www.medicareaustralia.gov.au/online**
- អញ្ជើញទៅកាន់ការិយាល័យ Medicare ក្នុងតំបន់លោកអ្នក
- ទូរស័ព្ទលេខ **132 011***

## តើខ្ញុំទទួលប្រយោជន៍អ្វីទៅ?

ជាឧទាហរណ៍មួយ បើលោកអ្នកឈានដល់កម្រិតកំណត់ Medicare Safety Net ហើយនោះ ការទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នកដែលគិតថ្លៃ $65 ពីលោកអ្នក នឹងធ្វើឲ្យលោកអ្នកទទួលប្រាក់បំណាច់ពី Medicare ចំនួន $34.30។ លោក អ្នកក៏នឹងទទួលប្រាក់ជំនួយ 80 ភាគរយនៃប្រាក់ចំណាយរបស់លោកអ្នកផងដែរ ដែលធ្វើឲ្យលោកអ្នកទទួលប្រាក់បំណាច់បន្ថែមចំនួន $24.60 ។ ហេតុនេះនៅក្នុងឧទាហរណ៍នេះ លោកអ្នកនឹងចំណាយតែ $6.10 ប៉ុណ្ណោះដើម្បីទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក។

### កម្រិតកំណត់ **Medicare Safety Net** មកទល់នឹងខែមករា ឆ្នាំ **2011**

| កម្រិតកំណត់ | តើសំរាប់អ្នកណា | របៀបគណនា | ប្រាក់បំណាច់ដល់លោកអ្នក |
|---|---|---|---|
| $399.60† | • អ្នកទាំងអស់ដែលមានប័ណ្ណ Medicare | ផ្អែកលើចំនួនប្រាក់ចន្លោះ | 100% នៃតារាងតម្លៃកំណត់ |
| $578.60† | • អ្នកមានប័ណ្ណសម្បទានសហព័ន្ធ<br>• គ្រួសារដែលទទួល FTB(A) | ថ្លៃចេញដោយខ្លួនឯងផ្ទាល់ | 80% នៃថ្លៃចេញដោយខ្លួនឯងផ្ទាល់ សំរាប់សេវាក្រៅមន្ទីរពេទ្យ |
| $1157.50† | • អ្នកទាំងអស់ដែលមានប័ណ្ណ Medicare | ថ្លៃចេញដោយខ្លួនឯងផ្ទាល់ | 80% នៃថ្លៃចេញដោយខ្លួនឯងផ្ទាល់ សំរាប់សេវាក្រៅមន្ទីរពេទ្យ |

† តួលេខនេះត្រូវបានកែតម្រូវឲ្យសមស្របនឹងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅថ្ងៃទី 1 ខែមករា រៀងរាល់ឆ្នាំ។

**ថ្លៃចេញដោយខ្លួនឯងផ្ទាល់** – ចំនួនខុសគ្នារវាងប្រាក់បំណាច់ Medicare និងចំនួនប្រាក់ដែលវេជ្ជបណ្ឌិតគិតថ្លៃពីលោកអ្នក។

**ចំនួនចន្លោះ** – ចំនួនខុសគ្នារវាងប្រាក់បំណាច់ Medicare និងថ្លៃក្នុងតារាងតម្លៃកំណត់។

**ថ្លៃក្នុងតារាងតម្លៃកំណត់** – ថ្លៃសំរាប់សេវាដែលកំណត់ដោយរដ្ឋាភិបាលអូស្ត្រាលី។

### តើមានសេវាណាខ្លះដែលរាប់បញ្ចូលទៅក្នុង Safety Net?

ឧទាហរណ៍ខ្លះនៃសេវាដែលការចំណាយរាប់បញ្ចូលទៅក្នុង Safety Net គឺ៖

- ការពិគ្រោះយោបល់ជាមួយគ្រូពេទ្យព្យាបាលជំងឺទូទៅ និងអ្នកឯកទេស
- ការធ្វើតេស្តសម្លេងអ៊ុលត្រា (ultrasounds)
- ចិត្តវេជ្ជសាស្ត្រ
- ការថត CT scans
- ការព្យាបាលដោយវិទ្យុសកម្ម
- ការពិនិត្យវិភាគជាលិកា
- MRIs
- តេស្តឈាម
- ថតកាំរស្មីអ៊ិក្ស (x-rays)
- តេស្ត pap smears ។

## ព័ត៌មានសំរាប់ជីដូនជីតា និងអ្នកថែទាំទាំងឡាយ

### តើខ្ញុំអាចទាមទារសុំថ្លៃចំណាយព្យាបាល ដែលខ្ញុំបានចំណាយសំរាប់កុមារដែលខ្ញុំកំពុងថែទាំបានឬទេ?

អាចធ្វើបាន។ ក្នុងភាពជាជីដូន ឬជីតាឬអ្នកថែទាំ លោកអ្នកអាចទាមទារសុំប្រាក់បំណាច់ Medicare ចំពោះថ្លៃចំណាយព្យាបាលដែលលោកអ្នកបានចំណាយសំរាប់កុមារដែលលោកអ្នកកំពុងថែទាំ។ អ្វីដែលលោកអ្នកត្រូវធ្វើគឺបង្ហាញឯកសារពាក់ព័ន្ធនឹងថ្លៃចំណាយរបស់លោកអ្នកទៅកាន់ Medicare ដើម្បីទទួលយកប្រាក់បំណាច់។

### តើខ្ញុំត្រូវចុះឈ្មោះកុមារនោះនៅក្នុងប័ណ្ណ Medicare របស់ខ្ញុំ ដើម្បីអាចឲ្យខ្ញុំទាមទារសុំប្រាក់ឬ?

ទេ លោកអ្នកមិនចាំបាច់ចុះឈ្មោះកុមារនោះនៅក្នុងប័ណ្ណ Medicare របស់លោកអ្នក ដើម្បីទាមទារសុំប្រាក់ Medicare ក្នុងការជួយបង់ថ្លៃដែលលោកអ្នកបានចំណាយនោះឡើយ។

### តើខ្ញុំត្រូវតែមានប័ណ្ណ Medicare ដែលមានឈ្មោះកុមារនោះដែរឬទេ?

កុមារនោះត្រូវតែចុះឈ្មោះជាមួយ Medicare និងបានចុះឈ្មោះនៅលើប័ណ្ណ Medicare មួយ។ ប៉ុន្តែ លោកអ្នកមិនចាំបាច់មានប័ណ្ណ Medicare ជាមួយលោកអ្នកទេ ក្នុងការទាមទារសុំប្រាក់បំណាច់។ វេជ្ជបណ្ឌិតអាចទាក់ទងទូរស័ព្ទសាកសួររបស់ Medicare Australia តាមលេខ **132 150*** និងសុំលេខប័ណ្ណ Medicare របស់កុមារនោះ ហើយប្រើលេខនេះសំរាប់ទាមទារសុំប្រាក់គិតថ្លៃដោយផ្ទាល់ (bulk bill) ។ បើវេជ្ជបណ្ឌិតនេះចេញប័ណ្ណទារប្រាក់ នោះមន្ត្រីសេវានៅការិយាល័យ Medicare ក្នុងតំបន់លោកអ្នកនឹងជួយលោកអ្នកក្នុងការទាមទារសុំប្រាក់បំណាច់។

### តើខ្ញុំអាចដាក់បន្ថែមកុមារនេះទៅក្នុងប័ណ្ណ Medicare របស់ខ្ញុំឬទេ?

ជីដូនជីតា និងអ្នកថែទាំអាចសុំឲ្យចុះឈ្មោះកុមារនោះទៅលើប័ណ្ណ Medicare របស់គាត់ ប៉ុន្តែជាការចាំបាច់ក្នុងការផ្តល់ឯកសារដើម្បីគាំទ្រសំណូមពរនេះ។ ឯកសារទាំងឡាយពីតុលាការ និងក្រសួងសេវាសហគមន៍ក្នុងរដ្ឋដែលពាក់ព័ន្ធអាចប្រើជាសក្ខីកម្មថាកុមារនោះស្ថិតនៅក្នុងការថែទាំយ៉ាងប្លូរផ្តាច់។

គេមិនអាចដកឈ្មោះកុមារចេញពីប័ណ្ណ Medicare របស់មាតា ឬបិតា ដោយគ្មានការអនុញ្ញាតពីមាតា ឬបិតាឡើយ។ ប៉ុន្តែ នៅពេលដែលកុមារនោះស្ថិតនៅក្នុងការថែទាំចំបងរបស់ជនណាម្នាក់ដែលមិនមែនជាមាតា ឬបិតា កុមារ

នោះអាចចុះឈ្មោះនៅក្នុងប័ណ្ណ Medicare របស់ជននោះ ឬចុះឈ្មោះនៅក្នុងប័ណ្ណ Medicare មួយសំរាប់ខ្លួនឯងផ្ទាល់ នៅពេលដែលកុមារនោះមានអាយុ 15 ឆ្នាំ។

**តើខ្ញុំអាចដាក់បន្ថែមកុមារនេះទៅក្នុងការចុះឈ្មោះ Medicare Safety Net របស់ខ្ញុំដែរឬទេ?**

ជាការសំខាន់ក្នុងការដឹងថា Medicare Safety Net មានការរឹតត្បិតខ្លះអំពីថាតើកុមារណាម្នាក់អាចចុះឈ្មោះនៅក្រោមបញ្ជីចុះឈ្មោះ Medicare Safety Net របស់ជីដូន ឬជីតា។ កុមារម្នាក់ៗអាចចុះឈ្មោះនៅក្នុង Medicare Safety Net បានចំនួនពីរប៉ុណ្ណោះយ៉ាងច្រើនបំផុត។

បើមាតាបិតាមានការចុះឈ្មោះពីរដោយឡែកពីគ្នា ហើយកុមារនេះមានឈ្មោះនៅក្នុងបញ្ជីនីមួយៗ កុមារនេះមិនអាចចុះឈ្មោះនៅក្នុង Medicare Safety Net របស់ជីដូនជីតាបានទេ។

ដោយសារតែមានស្ថានការណ៍ផ្សេងៗគ្នាមួយចំនួន ជីដូនជីតាគួរទាក់ទង Medicare ដើម្បីបញ្ជាក់អំពីសិទ្ធិទទួលរបស់គាត់ក្នុងការបន្ថែមឈ្មោះរបស់ចៅទៅក្នុងប័ណ្ណ Medicare និង/ឬក្នុងបញ្ជី Medicare Safety Net របស់គាត់។

## បញ្ជីឆែកមើលដោយសង្ខេប

សូមប្រើបញ្ជីឆែកមើលនេះដើម្បីធ្វើឲ្យច្បាស់ថា លោកអ្នកដឹងព័ត៌មានទាំងអស់អំពី Medicare ។

- ទូរស័ព្ទ **132 011*** ដើម្បីឆែកមើលថាតើឯកសារអ្វីទៅដែលលោកអ្នកត្រូវការយកទៅជាមួយ នៅពេលចុះឈ្មោះ។
- បំពេញពាក្យចុះឈ្មោះដែលអាចទទួលយកបានពីការិយាល័យ Medicare ក្នុងតំបន់លោកអ្នក **www.medicareaustralia.gov.au** ឬតាមទូរស័ព្ទលេខ **132 011***។
- បើលោកអ្នកជាជនអន្តោប្រវេសន៍ ឬជាអ្នកដាក់ពាក្យសុំរស់នៅជាអចិន្ត្រៃយ៍ (មានរួមទាំងអ្នកដាក់ពាក្យសុំទិដ្ឋាការការពារជាអចិន្ត្រៃយ៍) លោកអ្នកនឹងត្រូវរង់ចាំពេលមួយអាទិត្យ ក្រោយពីលោកអ្នកបានមកដល់ប្រទេសអូស្ត្រាលី មុនពេលចុះឈ្មោះនៅក្នុង Medicare ។ សូមចងចាំក្នុងការយកលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរទៅជាមួយ នៅពេលលោកអ្នកចុះឈ្មោះ។
- ចំពោះទារកទើបកើតថ្មី មន្ទីរពេទ្យនឹងជួយលោកអ្នកក្នុងការចុះឈ្មោះទារកលោកអ្នកនៅក្នុង Medicare ។
- នៅពេលលោកអ្នកទទួលប័ណ្ណ Medicare របស់លោកអ្នកជាលើកដំបូង សូមឆែកមើលព័ត៌មានទាំងអស់ដើម្បីធ្វើឲ្យប្រាកដថាមានព័ត៌មានចុះត្រឹមត្រូវ។
- បំផ្លាញប័ណ្ណ Medicare ចាស់ចោល នៅពេលលោកអ្នកទទួលប័ណ្ណផ្លាស់ថ្មីមួយ។
- ចងចាំក្នុងការយកប័ណ្ណ Medicare របស់លោកអ្នកទៅជាមួយ (និងប័ណ្ណសម្បទានរបស់លោកអ្នក បើលោកអ្នកមាន) នៅពេលទៅជួបវេជ្ជបណ្ឌិត ទៅមន្ទីរពេទ្យ ឬទៅទិញថ្នាំពេទ្យនៅឱសថស្ថាន។
- ប្រាប់ Medicare បើលោកអ្នកផ្លាស់ប្តូរអាសយដ្ឋានរបស់លោកអ្នក ដើម្បីធានាថាលោកអ្នកទទួលប័ណ្ណ Medicare ថ្មី និងព័ត៌មានសំខាន់ឯទៀត។
- ចុះឈ្មោះគ្រួសាររបស់លោកអ្នកសំរាប់ Medicare Safety Net ដោយប្រើពាក្យបំពេញនៅក្នុងកញ្ចប់នេះ នៅឯការិយាល័យ Medicare ឬនៅតាម **www.medicareaustralia.gov.au**— នេះគឺជាច់ដោយឡែកពីការចុះឈ្មោះនៅក្នុង Medicare ។
- ចុះព័ត៌មានអំពីគណនីធនាគាររបស់លោកអ្នកជាមួយ Medicare Australia ដើម្បីឲ្យលោកអ្នកអាចប្រើការទាមទារសុំប្រាក់បំណាច់នៅនឹងកន្លែងតែម្តង។
- នៅពេលទៅជួបអ្នកឯកទេស ត្រូវធ្វើឲ្យច្បាស់ថា លោកអ្នកទទួលការបញ្ជូនពីអ្នកឯកទេស ឬគ្រូពេទ្យព្យាបាលជំងឺទូទៅជាមុនសិន ហើយយកលិខិតបញ្ជូននេះទៅជាមួយលោកអ្នក។

- ចងចាំក្នុងការឆែកមើលកិច្ចព្រមព្រៀងថែទាំសុខភាពទៅវិញទៅមក និងការធានារ៉ាប់រងអ្វីទៅដែលលោកអ្នកត្រូវការ នៅពេលធ្វើដំណើរទៅបរទេស។

## ដើម្បីទទួលព័ត៌មានបន្ថែមអំពី Medicare

| | |
|---|---|
| វ៉ិបសាយ | **www.medicareaustralia.gov.au** |
| អ៊ីមែល | **medicare@medicareaustralia.gov.au** |
| សរសេរទៅ | **Medicare Australia**<br>**GPO Box 9822**<br>នៅក្នុងរដ្ឋធានីរបស់លោកអ្នក |
| ទូរស័ព្ទ | **132 011*** |
| TTY | **1800 552 152**** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ) |

*គិតថ្លៃទូរស័ព្ទ។

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

1577_12c.20.01.11